# ព្រះរាជាណាចក្រកម្ពុជា

ក្រុមហ៊ុន កូបេ យៃភែននីស រែស្តូរ៉ង **ជាតិ សាសនា ព្រះមហាក្សត្រ**

KOBE JAPANESE RESTAURANT

# កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១៦ថ្ងៃ គឺចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃចន្ទ ទី១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវ និងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន កូបេ យៃភែននីស រែស្តូរ៉ង មានអាសយដ្ឋាន ស្ថិតនៅភូមិ គ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាបដែលមានចំនួនកម្មករនិយោជិតសរុប ចំនួន ៩១នាក់ កម្មករនិយោជិតជាស្ត្រីមានចំនួន៣៧នាក់ មាននាយកឈ្មោះ គឹម វិបុល ជនជាតិខ្មែរ ជាតំណាងក្រុម ហ៊ុនកូបេយៃភែននីស រែស្តូរ៉ង បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករ និយោជិតរយៈពេល១៦ថ្ងៃ។

ជាកិច្ចចាប់ផ្តើមលោក គឹម វិបុល ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាល ជ្រៅដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនេះ បន្ទាប់មកលោកប្រធានអង្គប្រជុំមានមតិ សម្របសម្រួលអំពី ករណីខាងលើ និងពន្យល់មូលហេតុដោយសារតែបញ្ហាការផ្ទុះមេរោគឆ្លងជាសាកល កូវីដ-១៩ ធ្វើអោយភ្ញៀវមានការធ្លាក់ចុះយ៉ាងខ្លាំង ដូចនេះក្រុមហ៊ុន កូបេ យៃភែននីស រែស្តូរ៉ង និងកម្មករ និយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន០៨នាក់រយៈ១៦ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

២-ក្នុងអំឡុងនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតនិងទទួលបានប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាល ៣០ដុល្លារក្នុង១៦ថ្ងៃ ។

ខេត្តសៀមរាប,ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

បានឃើញ និងឯកភាព

តំណាងក្រុមហ៊ុន

តំណាងកម្មករនិយោជិត